# វិស័យកាត់ដេរប្រកួតប្រជែងនិងរីកលូតលាស់នៅកម្ពុជា

*"ដោយមានប្រាក់ចំណូលរបស់ខ្ញុំ ម្តាយខ្ញុំអាចសង់ផ្ទះថ្មមួយទំហំ ៥ គុណ ៧ ម៉ែត្រ ជាមួយដំបូលប្រក់ក្បឿង ហើយប្អូនស្រីខ្ញុំដែលមានអាយុ ១៥ ឆ្នាំ អាចបន្តការសិក្សារបស់នាងបាន ។"*

*--សុន ស៊ាន កម្មកររោងចក្រកាត់ដេរ អាយុ ២០ ឆ្នាំ*



***សុន ស៊ាន កម្មកររោងចក្រកាត់ដេរ***

**ភ្នំពេញ ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៧។** ក្នុងឯកសណ្ឋានព័ណ៌ខៀវចាស់ជាមួយជរក្រហម និងឈរនៅជាប់ម៉ាស៊ីនអ៊ុតដ៏ធំមួយ នៅក្នុងរោងចក្រកាត់ដេរមួយនៅក្នុងក្រុងភ្នំពេញ សុន ស៊ាន ដែលមានអាយុ ២០ ឆ្នាំ ញញឹមនិងឆ្លើយថា: *"ពេលនេះគ្រួសាររបស់ខ្ញុំមានជីវភាពរស់នៅល្អប្រសើរ"* នាងឈប់មួយភ្លែត និងនៅពេលកំពុងរុញកអាវចូលទៅក្នុងម៉ាស៊ីន បន្តថា *"ដោយមានប្រាក់ ចំណូលរបស់ខ្ញុំ ម្តាយខ្ញុំអាចសង់ផ្ទះថ្មមួយទំហំ ៥ គុណ ៧ ម៉ែត្រ ជាមួយដំបូលប្រក់ក្បឿង ហើយប្អូនស្រីខ្ញុំដែលមានអាយុ ១៥ ឆ្នាំ អាចបន្តការសិក្សារបស់នាង ។"*

សុន ស៊ាន គឺជាកម្មករម្នាក់នៃកម្មករកាត់ដេរជាច្រើនដែលមកពីខេត្តស្វាយរៀងជាខេត្តមួយក្រីក្ររបស់កម្ពុជា ស្ថិតនៅប្រមាណ ១២០ គីឡូម៉ែត្រ ប៉ែកខាងកើតក្រុងភ្នំពេញ។ នាងទទួលប្រាក់ចំណូលជាមធ្យមប្រហែល ៧០ ដុល្លាអាមេរិកក្នុងមួយខែ អាស្រ័យ លើបរិមាណការងារបន្ថែមម៉ោងដែលនាងទទួល ហើយរាល់ខែ ស៊ាន ផ្ញើប្រាក់ពី ៥០ ទៅ ៥០ ដុល្លាអាមេរិកទៅផ្ទះដើម្បីជួយឧបត្ថម្ភ ម្តាយមេម៉ាយរបស់នាងដែលមានអាយុជាង ៥០ ឆ្នាំ និងប្អូនស្រីរបស់នាងដែលរៀនថ្នាក់ទីប្រាំ។

មិត្តរួមការងាររបស់ ស៊ាន ឈ្មោះ វង់ ប៉ាក់ អាយុ ៣៩ ឆ្នាំ ញញឹមបង្កប់ដោយមោទនភាពនៅពេលទទួលសំណួរថាតើនាងបានជួយឧបត្ថម្ភគ្រួសាររបស់នាងឬទេជាមួយនឹងប្រាក់ចំណូលរបស់នាង។ *"ជាមួយប្រាក់ខែរបស់ខ្ញុំ ខ្ញុំចិញ្ចឹមម្តាយរបស់ខ្ញុំដែលមានអាយុ ៦៨ ឆ្នាំ កូនទាំងបួនរបស់ខ្ញុំ ហើយខ្ញុំអាចផ្តត់ផ្គង់ការសិក្សារបស់កូនខ្ញុំបាន"*។ អ្នកស្រី ប៉ាក់ គឺជាអ្នកមេគ្រួសារ។ កូនបីនាក់ ដែល មានអាយុ ១៤ ១២ និង ៧ ឆ្នាំ កំពុងទៅសាលារៀននៅពេលនេះ។

ស៊ាន និងប៉ាក់ ធ្វើការនៅរោងចក្រកាត់ដេរសម្លៀកបំពាក់ញូអាយឡែន (NIC) រួមជាមួយកម្មករជាង ៨០០ នាក់ផ្សេងទៀត។ NIC គឺជារោងចក្រមួយនៃរោងចក្រកាត់ដេរសម្លៀកបំពាក់ចំនួន ២៩០ នៅកម្ពុជា ដែលនាំចេញទំនិញទៅកាន់សហរដ្ឋអាមេរិក និងអឺរ៉ុប។ NIC ធ្វើប្រតិបត្តិការនៅក្នុងប្រទេសចំនួនប្រាំមួយ: កម្ពុជា ឥណ្ឌូណេស៊ី ស្រីលង្កា វៀតណាម លីទុយអានី និង ម៉ូរីហ្សីស។ ក្រុមហ៊ុននេះផលិតអាវធម្មតា និងអាវសម្រាប់បុរសនិងអាវស្ត្រី ដោយផ្គត់ផ្គង់អាវទាំងនេះឱ្យហាង

Marks & Spencers ក៏ដូចជាអតិថិជនកម្រិតខ្ពស់នៅបរទេសផងដែរ។ ក្នុងឆ្នាំ ២០០៥ រោងចក្រញូអាយឡែនគឺជាជ័យលាភីមួយនៃពានរង្វាន់ពលរដ្ឋសាជីវកម្មទីមួយ ដែលត្រូវបានឧបត្ថម្ភដោយសាខាហិរញ្ញប្បទានផ្នែកឯកជនរបស់ក្រុមធនាគារពិភពលោក ពោលគឺ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)។

ឧស្សាហកម្មកាត់ដេរកម្ពុជា គឺជាឧស្សាហកម្មចម្បងរបស់ប្រទេស និង គឺជាអ្នករកប្រាក់ចំណូលនាំមុខគេពីការនាំចេញ។ ក្នុងឆ្នាំ ២០០៦ ការនាំចេញមានទឹកប្រាក់សរុប ២,៥ ពាន់លានដុល្លាអាមេរិក ហើយវិស័យនេះផ្តល់ការងារដល់កម្មករចំនួន ៣៣០ ០០០ នាក់ដែលភាគច្រើនគឺជាស្ត្រីជនបទក្រីក្រដែលជួយឧបត្ថម្ភគ្រួសារ។ ជាសរុប ប្រជាជនប្រមាណជា ១,៧ លាននាក់ពឹងផ្អែកលើ ឧស្សាហកម្មកាត់ដេរដោយផ្ទាល់ឬដោយប្រយោល។

យោងតាមរបាយការណ៍ ពិពិធកម្មការនាំចេញ និងការបន្ថែមតម្លៃសម្រាប់កិច្ចអភិវឌ្ឍន៍មនុស្ស ដែលត្រូវបានបោះផ្សាយដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា នៅក្នុងខែ មិថុនា ឆ្នាំ ២០០៧ កម្មកររោងចក្រកាត់ដេរទទួលបានប្រាក់ចំណូលជាមធ្យម ៧៣ ដុល្លា អាមេរិកក្នុងមួយខែ ដែលនៅក្នុងនោះ ២៩ ភាគរយ គឺបានមកពីការងារបន្ថែមម៉ោង។

តំណាងឱ្យជិត ៨០ ភាគរយនៃការនាំចេញសរុបរបស់កម្ពុជា វិស័យនេះគឺសំខាន់ក្រៃលែងចំពោះសេដ្ឋកិច្ចកម្ពុជា។ ប៉ុន្តែកំណើននៃការប្រកួតប្រជែងពិភពលោកធ្វើឱ្យឧស្សាហកម្មនេះងាយរងគ្រោះ ដូច្នេះ គេចាំបាច់ត្រូវមានអភិក្រមផ្សេងៗដើម្បីជួយឱ្យ ឧស្សាហកម្មនេះអាចទ្រទ្រង់ខ្លួនឯងបាន។

ប្រធានធនាគារពិភពលោក លោក រ៉ូប៊ឺត ហ្សេអេលិក (Robert Zoellick) បានទស្សនារោងចក្រកាត់ដេរមួយ និងបានជួប ជាមួយតំណាងផ្នែកឯកជនមួយចំនួន។ វិស័យកាត់ដេរនៅកម្ពុជាគឺជាឧស្សាហកម្មធំបំផុតរបស់កម្ពុជា ដែលមានតម្លៃ ២,៥ ពាន់ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៦ និង តំណាងឱ្យ ៨០ ភាគរយនៃការនាំចេញ។ ការពាក់ព័ន្ធរបស់លោក ហ្សេអេលិក ជាមួយ នឹងវិស័យកាត់ដេរនេះគឺចាប់ផ្តើមតាំងពីឆ្នាំ ២០០១ នៅពេលដែលលោកក្នុងឋានៈជាតំណាងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក បានផ្តល់កម្មវិធីគាំទ្រមួយចំពោះឧស្សាហករកម្ពុជាដែលបានផ្តល់គ្រឿងលើកទឹកចិត្តឱ្យមានអនុលោមភាពជាមួយនឹងស្តង់ដារពលកម្ម ដែលកំណត់ដោយអង្គការពលកម្មអន្តរជាតិ (ILO)។ វិស័យកាត់ដេរកម្ពុជាបានរីកលូតលាស់យ៉ាងនឹងនរ សូម្បីតែនៅក្រោយពេលបញ្ចប់កិច្ចព្រមព្រៀងស្តីពីពហុវាយនភណ្ឌនៅក្នុងឆ្នាំ ២០០៥ ដែលធ្លាប់បានទទួលការការពារខ្លះពីផលិតករធំៗក្តី។

លោក ហ្សេអេលិក បាននិយាយថាការមើលឃើញកម្លាំងនៃវិស័យនេះគឺជាការសប្បាយរីករាយ និងថាជោគជ័យនៃវិស័យនេះ ផ្តល់នូវមេរៀនអំពីតួនាទីដ៏សំខាន់នៃការគោរពតាមស្តង់ដារដែលអាចទទួលយកបានជាអន្តរជាតិក្នុងការកសាងទំនុកចិត្តជាមួយអ្នកទិញ និងវិនិយោគិនបរទេស។

*"មេរៀនទាំងនេះ ប្រើប្រាស់បានកាន់តែយ៉ាងទូលំទូលាយ។ មេរៀនទាំងនេះ អាចត្រូវបានយកទៅអនុវត្ត ហើយវាមិនត្រឹមតែធ្វើអោយវិស័យកាត់ដេរទទួលបានជោគជ័យប៉ុណ្ណោះទេ វាក៏នឹងធ្វើអោយវិស័យដទៃទៀតទទួលបានជោគជ័យផងដែរ ហើយប្រទេសកម្ពុជា អាចកសាងនូវកេរ្តិ៍ឈ្មោះផលិតផលជាលក្ខណៈអន្តរជាតិមួយ សំរាប់ផលិតកម្មដែលមានការទទួល ខុសត្រូវ*

*ក្នុងសង្គម ក៏ដូចជាការអភិវឌ្ឍធនធាន និងទេសចរណ៍ផងដែរ។ កេរ្តិ៍ឈ្មោះនោះ នឹងជួយកម្ពុជាទ្រទ្រង់កំណើនខ្ពស់បានយូរអង្វែង និង ប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ក្នុងលក្ខណៈប្រកួតប្រជែងជាសកលដ៏លំបាក ”។*

ធនាគារពិភពលោកកំពុងផ្តល់ជំនួយដ៏សំខាន់ជូនដល់វិស័យកាត់ដេរដើម្បីលើកស្ទួយភាពប្រកួតប្រជែងពិភពលោករបស់វិស័យនេះ ដោយសហការជាមួយរដ្ឋាភិបាលនិងផ្នែកឯកជន លើកំណែទម្រង់មួយចំនួនដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ជាពិសេសកំណែទម្រង់ ទាំងឡាយដែលនឹងកាត់បន្ថយពេលវេលា និងចំណាយនៅក្នុងការនាំចូលវត្ថុធាតុដើម និងការនាំចេញផលិតផលសម្រេច។

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ IFC ផ្តល់សេវាប្រឹក្សាជូនវិស័យនេះតាមរយៈ កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់មេគង្គរបស់ខ្លួន ដែលទទួលមូលនិធិពីពហុអ្នកផ្តល់ជំនួយ។ ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ បុគ្គលិកប្រឹក្សា IFC បាននិងកំពុងជម្រុញការទទួលខុសត្រូវផ្នែកសង្គមកិច្ចរបស់សាជីវកម្ម តាមរយៈការបណ្តុះបណ្តាលលើជំនាញទំនាក់ទំនងមនុស្ស ជូនអ្នកគ្រប់គ្រងរោងចក្រកាត់ដេរ និងដោយជួយធានាឱ្យបាននូវនិរន្តរភាពរយៈពេលវែងសម្រាប់កម្មវិធីឃ្លាំមើលពលកម្ម និងដោះស្រាយបញ្ហារបស់អង្គការ ILO ពោលគឺគម្រោងរោងចក្រល្អប្រសើរកម្ពុជា។ IFC ក៏រួមគ្នាជាមួយអង្គការ ILO ផងដែរនៅក្នុងការជួយសម្រួលវេទិកាអ្នកទិញ ដែលផ្តល់ឱកាសឱ្យអ្នកទិញនិងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀតបានជួបប្រជុំគ្នាទៀងទាត់។

លោក រីឆាដ រ៉ែនខិន (Richard Ranken) នាយក IFC សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលបានអមដំណើរលោកប្រធាន ហ្សេអេលិក នៅក្នុងដំណើរទស្សនារោងចក្រញូអាយឡែន បាននិយាយថាការទទួលខុសត្រូវផ្នែកសង្គមកិច្ចរបស់សាជីវកម្ម ក៏ដូចជាកិច្ចសហការគ្នានៅក្នុងចំណោមអ្នកទិញ រដ្ឋាភិបាល តំណាងឧស្សាហកម្ម និង តំណាងកម្មករ គឺមានលក្ខណៈចាំបាច់ខ្លាំង សម្រាប់ជោគជ័យនៃឧស្សាហកម្មកាត់ដេរ ដើម្បីពង្រឹងថែមទៀតនូវជំហរប្រកួតប្រជែងនៃឧស្សាហកម្មនេះ។ "ហេដ្ឋារចនាសម្ព័ន្ធ បន្ថែមទៀត និងកាន់តែល្អប្រសើរ គឺចាំបាច់ខ្លាំងផងដែរនៅកម្ពុជា ហើយ IFC ត្រៀមខ្លួនជាស្រេចដើម្បីជួយគាំទ្រកិច្ចការ នេះផងដែរ។"

ធនាគារពិភពលោកបានជួយគាំទ្ររដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៏ផ្នែកឯកជន តាមរយៈគម្រោងសម្រួល និងភាពប្រកួតប្រជែងពាណិជ្ជកម្ម ជាមួយនឹងជំនួយឥតសំណង ១០ លានដុល្លាអាមេរិក។ ជំនួយនេះរាប់បញ្ចូលទាំងការជួយឧបត្ថម្ភរបស់ធនាគារពិភពលោកចំពោះគម្រោងរោងចក្រល្អប្រសើរកម្ពុជារបស់អង្គការ ILO។

*ដើម្បីព័ត៌មានបន្ថែមអំពីកម្មវិធីរបស់ធនាគារពិភពលោកនៅក្នុងប្រទេសកម្ពុជា សូមមើលវិបសាយភាសាអង់គ្លេសៈ http://www.worldbank.org/kh*